**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ១៩៥៤ ព.ណ.អ.ទ.៦

ថ្ងៃព្រហស្បតិ៍ ៧កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០២១

# សេចក្តីជូនដំណឹង

## ស្តីពី

## ថ្លៃលក់រាយប្រេងឥន្ធនៈនៅតាមស្ថានីយ

- យោងប្រកាសអន្តរក្រសួងលេខ១៧២០ពណ. អវង.ប្រក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងក្រសួងរ៉ែ និងថាមពល ស្តីពីការកំណត់រូបមន្តសម្រាប់កែសម្រួលថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា
- យោងលើការព្រមព្រៀង លើរូបមន្តកំណត់តម្លៃជាមួយក្រុមហ៊ុនប្រេងឥន្ធនៈដែលប្រកបអាជីវកម្មនៅកម្ពុជា
- យោងការប្រែប្រួលនៃតម្លៃប្រេងឥន្ធនៈលើទីផ្សារក្នុងតំបន់ និងអន្តរជាតិ

ផ្អែកតាមតម្លៃមធ្យមប្រេងឥន្ធនៈលើទីផ្សារអន្តរជាតិ ថ្លៃលក់រាយប្រេងឥន្ធនៈពីថ្ងៃទី០១ ដល់ ១៥ ខែកក្កដា ឆ្នាំ២០២១ នឹងត្រូវលក់ ៤.១៦០រៀល/១លីត្រ សម្រាប់សាំងធម្មតា EA92 និង ៣.៧៦០រៀល/លីត្រ សម្រាប់ប្រេងម៉ាស៊ូត។

ដើម្បីជួយសម្រួលដល់ជីវភាពរបស់ប្រជាជន និងដោយមានការរួមចំណែកពីក្រុមហ៊ុនចែកចាយប្រេងឥន្ធនៈនៅកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានសម្រេចបញ្ចុះតម្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា ចំនួន៤សេនដុល្លារ/លីត្រ ។

ដូច្នេះថ្លៃលក់រាយប្រេងឥន្ធនៈសម្រាប់អនុវត្ត **ចាប់ពីថ្ងៃទី០១ ដល់ ១៥ ខែកក្កដា ឆ្នាំ២០២១** នឹងចុះមក ៤.០០០ រៀល/លីត្រ សម្រាប់សាំងធម្មតា EA92 និង ៣.៦០០ រៀល/លីត្រ សម្រាប់ប្រេងម៉ាស៊ូត ។

ការគណនាថ្លៃលក់រាយប្រេងឥន្ធនៈមានលម្អិតដូចតារាងខាងក្រោម៖

**តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារកម្ពុជា**

| ល.រ | អធិប្បាយ | ប្រេងសាំងធម្មតា/លីត្រ (Gasoline 92) | | ប្រេងម៉ាស៊ូត/លីត្រ (Gasoil) | |
|---|---|---|---|---|---|
| ១ | Average MOPS | | ០,៥០៦៣ ដុល្លារ | | ០,៥០១៨ ដុល្លារ |
| ២ | ពន្ធ៖ | | ០,១៨៤៧ ដុល្លារ | | ០,០៧៤២ ដុល្លារ |
| | ពន្ធគយ | ០,០៦៣៥ ដុល្លារ | | ០,០០០០ ដុល្លារ | |
| | អាករបន្ថែម | ០,០២០០ ដុល្លារ | | ០,០៤០០ ដុល្លារ | |
| | អាករពិសេស | ០,១០១៣ ដុល្លារ | | ០,០៣៤២ ដុល្លារ | |
| ៣ | PREMIUM | | ០,២០ ដុល្លារ | | ០,២៣ ដុល្លារ |
| ៤ | អាករលើតម្លៃបន្ថែម (១០% នៃ ១+២+៣) | | ០,០៨៩១ ដុល្លារ | | ០,០៨០៦ ដុល្លារ |
| ៥ | ថ្លៃលក់រាយ/លីត្រ (គិតជាដុល្លារ) | | ០,៩៨០១ ដុល្លារ | | ០,៨៨៦៦ ដុល្លារ |
| ៦ | ថ្លៃលក់រាយ/លីត្រ (គិតជារៀល) | | ៣.៩៩២ រៀល | | ៣.៦១១ រៀល |
| ៧ | តម្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជាដុល្លារ) | | ០,៩៨ ដុល្លារ | | ០,៨៩ ដុល្លារ |
| ៨ | តម្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជារៀល) | | ៤.០០០ រៀល | | ៣.៦០០ រៀល |

សម្គាល់៖ អត្រាប្តូរប្រាក់ផ្លូវការ ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១ ដែលស្មើនឹង៤.០៧៣រៀល/ដុល្លារអាមេរិក

ក្រសួងពាណិជ្ជកម្ម

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ៖ (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

## តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិ

| ថ្ងៃខែឆ្នាំ | ប្រេងសាំងធម្មតា/ធុង EA 92 (USD/Barrel) | ប្រេងម៉ាស៊ូត/ធុង Gasoil (USD/Barrel) |
|---|---|---|
| ១៦ មិថុនា ២០២១ | ៧៩,២៦ | ៨០,០៣ |
| ១៧ មិថុនា ២០២១ | ៧៩,០២ | ៧៩,៦៩ |
| ១៨ មិថុនា ២០២១ | ៧៧,៩២ | ៧៨,៣៧ |
| ២១ មិថុនា ២០២១ | ៧៩,១២ | ៧៩,១១ |
| ២២ មិថុនា ២០២១ | ៨០,១៨ | ៧៩,៧៣ |
| ២៣ មិថុនា ២០២១ | ៨១,៥៣ | ៨០,៦៦ |
| ២៤ មិថុនា ២០២១ | ៨២,១៦ | ៨០,៦៥ |
| ២៥ មិថុនា ២០២១ | ៨២,១៧ | ៨០,៥៣ |
| ២៨ មិថុនា ២០២១ | ៨១,៥៩ | ៨០,៣៣ |
| ២៩ មិថុនា ២០២១ | ៨០,៧៩ | ៧៩,៣៣ |
| ៣០ មិថុនា ២០២១ | ៨១,៨០ | ៧៩,២៦ |
| **មធ្យមភាគ ១១ថ្ងៃ** | **៨០,៥០៣៦** | **៧៩,៧៩០០** |
| **មធ្យមភាគ (ដុល្លារ/លីត្រ)** | **០,៥០៦៣** | **០,៥០១៨** |

**ក្រាហ្វិកបម្រែបម្រួលថ្លៃលក់រាយប្រេងឥន្ធនៈពីថ្ងៃទី១៦ ខែមីនា ដល់ ០១ ខែមិថុនា ឆ្នាំ២០២១**




សូមបញ្ជាក់ថា ក្រសួងពាណិជ្ជកម្មមិនមែនជាអ្នកកំណត់ថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជាទេ គឺក្រសួងគ្រាន់តែស្រង់តម្លៃឡើង-ចុះ នៃប្រេងតាមទីផ្សារអន្តរជាតិ មកគណនាតាមប្រកាសដូចមានក្នុងឯកសារយោងខាងលើតែប៉ុណ្ណោះ ។

អាស្រ័យហេតុនេះ សូមសាធារណៈជនមេត្តាជ្រាបជាព័ត៌មាន និងសូមគ្រប់ស្ថានីយលក់រាយប្រេងឥន្ធនៈទាំងអស់ប្រតិបត្តិតាមការចាំបាច់។